# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

## ការិយាល័យអគ្គនាយកក្រសួងអប់រំ

**440 NORTH BROAD STREET, SUITE 301**

**PHILADELPHIA, PENNSYLVANIA 19130**

**WILLIAM R. HITE, JR., Ed.D.**
*អគ្គនាយកក្រសួងអប់រំ*

ថ្ងៃទី២ ខែមិថុនា ២០១៦

ជូនចំពោះ មាតាបិតា និង អាណាព្យាបាលៈ

ក្នុងខណៈដែលការបញ្ចប់ឆ្នាំសិក្សាខិតជិតមកដល់ សាលារបស់យើងទាំងអស់ចាប់ផ្តើមមានបញ្ហា ដែលយើងហៅថា «ការរយាលនៅនិទាឃរដូវ» និង «ការធ្លាក់ចុះនៅខែមិថុនា»។ នេះគឺជាលំនាំនៃបញ្ហាដែលវត្តមានរបស់សិស្សានុសិស្សចាប់ផ្តើមធ្លាក់ចុះនៅខែឧសភា ហើយកាន់តែធ្លាក់ចុះថែមទៀតនៅខែមិថុនា។ យើងខ្ញុំដឹងថាអវត្តមានខ្លះ គឺមិនអាចចៀសវាងបាន ឧទាហរណ៍ដូចជានៅពេលសិស្សមានបញ្ហាសុខភាព។ ក៏ប៉ុន្តែយើងខ្ញុំក៏បានដឹងដែរថា បើសិនជាសិស្សមិនបានមករៀនច្រើនថ្ងៃពេក វាអាចបណ្តាលឲ្យសិស្សរៀនមិនទាន់គេ។ ដើម្បីធ្វើយ៉ាងណាឲ្យកូនរបស់លោកអ្នកទទួលការអប់រំដ៏ល្អបំផុត ខ្ញុំបាទសុំឲ្យលោកអ្នកជួយយើងខ្ញុំ ធ្វើយ៉ាងណាឲ្យកូនរបស់លោកអ្នកមករៀនឲ្យបានទៀងទាត់ និងទាន់ពេលវេលាជារៀងរាល់ថ្ងៃ រហូតដល់ថ្ងៃរៀនចុងក្រោយបង្អស់។ សូមពិភាក្សាជាមួយកូនរបស់លោកអ្នកអំពីសារៈសំខាន់នៃការមករៀន សម្រាប់ជោគជ័យក្នុងការសិក្សា និងការខិតខំសិក្សាគ្រប់ថ្នាក់រៀនទាំងអស់របស់ពួកគេ។ **ការបង្ហាត់បង្រៀននៅតែបន្ត ហើយវត្តមានអវត្តមានត្រូវបានកត់ទុកជារៀងរាល់ថ្ងៃដោយក្រសួងអប់រំ និងរាប់បញ្ចូលរហូតដល់ថ្ងៃរៀនចុងក្រោយបង្អស់ គឺនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦។**

ទាំងនេះគឺជាឱវាទមួយចំនួន ដើម្បីជួយឲ្យសិស្សមករៀនឲ្យបានទៀងទាត់ នៅចុងបញ្ចប់នៃឆ្នាំសិក្សាៈ

- ធ្វើយ៉ាងណាឲ្យកូនមករៀនជារៀងរាល់ថ្ងៃ លើកលែងតែពួកគេពិតជាឈឺមែន។
- ចៀសវាងកុំឲ្យមាន វិស្សមកាល ឬ ការណាត់ជួប នៅពេលដែលសាលានៅបង្រៀន។
- ធ្វើយ៉ាងណាឲ្យកូនចូលគេងឲ្យបានទៀងទាត់ពេលវេលា។
- និយាយជាមួយ គ្រូ និង អ្នកផ្តល់ឱវាទ ដើម្បីសុំយោបល់ពីពួកគាត់ បើសិនជាកូនរបស់លោកអ្នកចាប់ផ្តើមមិនចង់ទៅរៀន។

យើងខ្ញុំចង់ឲ្យកូនលោកអ្នកមានជោគជ័យក្នុងការសិក្សា! បើសិនជាលោកអ្នកមានសំណួរអ្វី ឬ ត្រូវការព័ត៌មានបន្ថែម សូមទាក់ទងទៅសាលារបស់កូនលោកអ្នក។

សូមអរគុណទុកជាមុនចំពោះ ជំនួយ និង ការគាំទ្រ របស់លោកអ្នក។

ដោយសេចក្តីស្មោះស្ម័គ្រ



William R. Hite, Jr., Ed.D.